# សង្កេតការណ៍ ២

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



# នួន ជា

ខែកញ្ញា ឆ្នាំ២០១១

## មាតិកា


សេចក្តីផ្តើម ១
ការវាយតម្លៃរបស់អ្នកជំនាញ ២
ការសួរដេញដោលពីវិធីសាស្ត្រ ៥
វត្តមានរបស់ជនជាប់ចោទ ៨
បញ្ហាផ្សេងៗ ៩
ការយល់ឃើញទូទៅ ១៣
សន្និដ្ឋាន ១៨



ក្រុមសង្កេតការណ៍ :
គីម ម៉ារីយ៉ាន, ឌី សុជាតា,
លឹម ជ័យទត្ត និង ចាន ប្រាថ្នា



មជ្ឈមណ្ឌលឯកសារកម្ពុជា ◆ ស្វែងរកការពិតដើម្បីការចងចាំ និងយុត្តិធម៌ ◆ www.dccam.org



រូបថត : អ.វ.ត.ក

អៀង សារី ចូលរួមក្នុងសាលសវនាការក្នុងឋានៈជាអ្នកអង្កេតការណ៍

# សវនាការមុនអង្គសេចក្តីលើសម្បទាជនជាប់ចោទក្នុងសំណុំរឿង០០២

## ថ្ងៃទី២៩-៣១ ខែសីហា ឆ្នាំ២០១១

*ដោយ គីម ម៉ារីយ៉ាន, ឌី សុជាតា, លឹម ជ័យទត្ត និង ចាន ប្រាថ្នា*

## ១) សេចក្តីផ្តើម

សំណុំរឿង ០០២ គឺជាសំណុំរឿងដែលមានសារសំខាន់បំផុត ដោយសំណុំរឿងនេះមានជនជាប់ចោទចំនួនបួនរូប ដែលត្រូវបានជឿជាក់ថាជាមេដឹកនាំជាន់ខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[១] ។ ជនជាប់ចោទទីមួយគឺ នួន ជា អាយុ៨៥ឆ្នាំ ជាអនុលេខាបក្ស និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាប់ចោទទីពីរគឺ ខៀវ សំផន អាយុ៨០ឆ្នាំ ជាគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាប់ចោទទីបី គឺ អៀង សារី អាយុ៨៦ឆ្នាំ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិបក្សកុម្មុយនិស្តកម្ពុជា ជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស និងជនជាប់ចោទទីបួន គឺ អៀង ធីរិទ្ធ អាយុ៧៩ឆ្នាំ ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្វីដែលធ្វើឲ្យសាធារណជនមានការចាប់អារម្មណ៍ និងមានការព្រួយបារម្ភយ៉ាងខ្លាំងនោះ គឺបញ្ហាសុខភាពរបស់ជនជាប់ចោទទាំងបួនរូប ។ ការព្រួយបារម្ភនេះបានកើតចេញពីបញ្ហាវ័យចំណាស់របស់ជនជាប់ចោទ និងបញ្ហាសុខភាពដែលកំពុងតែមានសភាពកាន់តែទ្រុឌទ្រោម ។ ជនជាប់ចោទ នួន ជា កំពុងមានបញ្ហាដែលបណ្តាលមកពីការដាច់សសៃឈាមក្នុងខួរក្បាល សម្ពាធឈាមឡើងខ្ពស់ និងមានបញ្ហាឈឺចង្កេះជាដើម ។ ជនជាប់ចោទ អៀង សារី ត្រូវបានអះអាងថាមានបញ្ហាផ្នែកតម្រងនោម និងឆ្អឹងខ្នង ។ ជនជាប់ចោទ អៀង ធីរិទ្ធ កំពុងមានបញ្ហាសុខភាពទាំងខាងផ្លូវកាយនិងខាងបញ្ហាស្មារតី ។ ជនជាប់ចោទ ខៀវ សំផន ដែលហាក់បីដូចជាមានសុខភាពនៅល្អជាងជនជាប់ចោទទាំងបីរូបផ្សេង ទៀត ។

សវនាការមុនអង្គសេចក្តីដែលបានប្រព្រឹត្តធ្វើឡើងនៅថ្ងៃទី២៩ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ គឺជាសវនាការលើកទីពីរបន្ទាប់ពីសវនាការបឋមកាលពីថ្ងៃទី២៧ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ



**និស្សិតសាកលវិទ្យាល័យកំពុងចូលសាលសវនា**

---

[១] ប្រល័យពូជសាសន៍ ៖ តើជនណាខ្លះដែលជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនឹងត្រូវវិនិច្ឆ័យទោស? សារសំខាន់នៃសំណុំរឿង ០០២, មជ្ឈមណ្ឌលឯកសារកម្ពុជា

២០១១កន្លងទៅ ។ សវនាការបឋមលើកទីពីរនេះ ត្រូវបានធ្វើឡើងដើម្បីធ្វើការជជែកដេញដោលទៅលើរបាយការណ៍របស់អ្នកជំនាញ គឺលោកសាស្ត្រាចារ្យ ចន ខាំប៊ែល និងធ្វើការឆ្លើយតបទៅនឹងការស្នើសុំតែងតាំងអ្នកជំនាញដើម្បីពិនិត្យទៅលើសម្បទារបស់ជនជាប់ចោទ នួន ជា ។ ពាក្យថា "សម្បទារបស់ជនជាប់ចោទ" គឺសំដៅទៅលើសមត្ថភាពខាងផ្លូវកាយ និងខាងបញ្ញាស្មារតីរបស់ជនជាប់ចោទក្នុងការចូលរួមនៅក្នុងសវនាការ ។ ការចូលរួមរបស់ជនជាប់ចោទនៅក្នុងសវនាការគឺមានសារសំខាន់ណាស់ ព្រោះវាជាការធានានូវការកាត់ក្តីដោយត្រឹមត្រូវនិងយុត្តិធម៌ និងដើម្បីជៀសវាងនូវសវនាការកំបាំងមុខដែលអាចត្រូវបានទទួលរងការរិះគន់ពីមតិសាធារណជន និងអ្នកជំនាញផ្នែកច្បាប់ថាជាការកាត់សេចក្តីដោយអយុត្តិធម៌ ។

## ២) ការវាយតម្លៃរបស់អ្នកជំនាញទៅលើសម្បទារបស់ជនជាប់ចោទ

អនុលោមតាមវិធាន៣១(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងអ្នកជំនាញដើម្បីធ្វើការវាយតម្លៃទៅលើសមត្ថភាពខាងសុខភាពផ្លូវកាយ និងបញ្ញាស្មារតីរបស់ជនជាប់ចោទ ដោយយោងទៅលើសំណើសុំរបស់មេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នួន ជា និងអៀង សារី ដែលបានដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូងកាលពីខែមីនា ឆ្នាំ ២០១១ ។ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១ លោកសាស្ត្រាចារ្យ ចន ខាំប៊ែល ដែលមានសញ្ជាតិ ណូវែលហ្សេឡង់ ត្រូវបានតែងតាំងជាអ្នកជំនាញដើម្បីធ្វើការពិនិត្យ និងវាយតម្លៃទៅលើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទបីរូបគឺ នួន ជា អៀង សារី និងអៀង ធីរិទ្ធ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល មានជំនាញខាងជំងឺមនុស្សចាស់ និងធ្វើជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យវេជ្ជសាស្ត្រនៅប្រទេស ណូវែលហ្សេឡង់ និងក្រោយមក លោកទទួលបានតំណែងជាសាស្ត្រាចារ្យខាងមើលថែទាំមនុស្សចាស់ ។

នៅក្នុងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ជាថ្ងៃទីមួយនៃសវនាការស្តីពីការសួរដេញដោលទៅលើបញ្ហាកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ លោកសាស្ត្រាចារ្យ ចន ខាំប៊ែល បានឆ្លើយតបទៅនឹងសំណួរជាច្រើនរបស់ចៅក្រមអន្តរជាតិ ស៊ីលវៀ ខាតវ្រ៉ាយត៍ ចំពោះបញ្ហាជំងឺមនុស្សចាស់ថា ជាទូទៅជំងឺចុះខ្សោយសតិបញ្ញាមានការប៉ះពាល់ច្រើនទៅលើមនុស្សចាស់ ពេលខ្លះក៏អាចកើតឡើងចំពោះមនុស្សដែលមានវ័យក្មេងខ្លះដែរ ។ ចំពោះមនុស្សដែលមានវ័យក្មេងវិញ គឺវាមានផលប៉ះពាល់តែមួយរយៈពេលប៉ុណ្ណោះ ក៏ប៉ុន្តែសម្រាប់មនុស្សចាស់ វាអាចវិវឌ្ឍន៍ទៅកាន់ភាពធ្ងន់ធ្ងរ នៅពេលដែលអាយុកាន់តែច្រើនឡើង ។ លោកសាស្ត្រាចារ្យ ខាំប៊ែល ក៏បានឆ្លើយតបទៅនឹងសំណួររបស់លោកស្រីចៅក្រម ខាតវ្រ៉ាយត៍ លើវិធីសាស្ត្រនៃការវាយតម្លៃថា ការធ្វើកោសល្យវិច័យទៅលើជនជាប់ចោទ នួន ជា និង អៀង ធីរិទ្ធ គឺលោកបានឈរលើមូលដ្ឋានឯកសារមួយចំនួនដូចជា របាយការណ៍ពេទ្យជាលាយលក្ខណ៍អក្សរ របាយការណ៍របស់លោកសាស្ត្រាចារ្យ កា ស៊ិនបូណាត ដែលជាអ្នកជំនាញខាងចិត្តវិទ្យា របាយការណ៍សុខភាពពីមន្ទីរពេទ្យកាលម៉ែត មន្ទីរពេទ្យបំរ៉ុងរ៉ាត (ប្រទេសថៃ)



***សាស្ត្រាចារ្យ ចន ខាំប៊ែល ផ្តល់សក្ខីកម្មទៅលើរបាយការណ៍សុខភាពជនជាប់ចោទ***

និងរបាយការណ៍ពីមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការពិនិត្យមើលទៅលើឯកសារ និងហ្វីលផ្សេងៗ រួមទាំងការធ្វើពិសោធន៍ការចងចាំរបស់ជនជាប់ចោទតាមរយៈវិធីសាស្ត្រពិនិត្យមើលទៅលើការស៊ីចង្វាក់គូរវាងលេខនៅក្នុងនាឡិកា និងតួអក្សរ ដែលការធ្វើពិសោធរបៀបនេះ គឺធ្វើតែទៅលើជនជាប់ចោទ អៀង ធីរិទ្ធ តែម្នាក់ប៉ុណ្ណោះ ។

ការវាយតម្លៃទៅលើសម្បទារបស់ជនជាប់ចោទ នួន ជា លោកសាស្ត្រាចារ្យ ខាំប៊ែល បានបញ្ជាក់ថា ជនជាប់ចោទ នួន ជា មានបញ្ហាសុខភាពមួយចំនួនដូចជា ជំងឺសរសៃឈាមបេះដូង ជំងឺសរសៃឈាមក្នុងខួរក្បាល សាច់ដុំ និងគ្រោងឆ្អឹង ប៉ុន្តែមិនមានសញ្ញាណាមួយដែលបញ្ជាក់ថា ជនជាប់ចោទ នួន ជា មានបញ្ហាផ្នែកបញ្ញាស្មារតីឡើយ ។ នៅក្នុងការឆ្លើយតបទៅនឹងសំណួរចៅក្រមខាតប្រ៊ាយត៍ លោកសាស្ត្រាចារ្យ ខាំប៊ែល បានធ្វើការសង្ខេបទៅលើប្រភេទជំងឺទាំងបួននោះ ដូចជា ៖

- ជំងឺសរសៃឈាមបេះដូង អាចបណ្តាលឲ្យមានសភាពគានតឹងពេលអង្គុយ តឹងទ្រូង ។
- ជំងឺសរសៃឈាមក្នុងខួរក្បាល អាចបណ្តាលឲ្យធុញទ្រាន់ពេលនៅក្នុងសវនាការយូរ ។
- ជំងឺសាច់ដុំ និងគ្រោងឆ្អឹងរបស់ជនជាប់ចោទ នួន ជា អាចបណ្តាលឲ្យមានការពិបាកក្នុងការអង្គុយយូរ ។

លោកសាស្ត្រាចារ្យ ខាំប៊ែល រកមិនឃើញថា ជំងឺសរសៃឈាមក្នុងខួរក្បាលនេះអាចបណ្តាលឲ្យបន្ថយនូវការយល់ដឹងនោះទេ ។ នៅក្នុងសវនាការ ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា ខ្លួនអាចចូលរួមក្នុងសវនាការបានត្រឹមតែរយៈពេលប្រហែលមួយម៉ោងទៅមួយម៉ោងកន្លះប៉ុណ្ណោះ បន្ទាប់ពីនោះខ្លួនមិនអាចធ្វើការផ្ចង់អារម្មណ៍ជាមួយនឹងដំណើរការសវនាការបានឡើយ ។ ចំពោះការលើកឡើងរបស់ជនជាប់ចោទ នួន ជា នេះ លោកសាស្ត្រាចារ្យ ខាំប៊ែល បានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះអាចរៀបចំសវនាដែលអាចមានរយៈខ្លីល្មមសម្រាប់ជនជាប់ចោទ នួន ជា ឬអាចរៀបចំឲ្យជនជាប់ចោទចូលរួមសវនាការពីបន្ទប់រង់ចាំបាន ។

ចំពោះជនជាប់ចោទ អៀង ធីរិទ្ធ លោកសាស្ត្រាចារ្យ ខាំប៊ែល បានសន្និដ្ឋានថា ជនជាប់ចោទមានបញ្ហាខាងស្មារតី និងប្រព័ន្ធសរសៃប្រសាទ ។ ថែមទាំងមានបញ្ហាជំងឺធ្ងន់ធ្ងរអាចបាត់បង់ស្មារតីដោយសារថ្នាំ ដែលជនជាប់ចោទ អៀង ធីរិទ្ធ ប្រើប្រាស់សព្វថ្ងៃ និងបរិស្ថានសង្គមដែលខ្លួនកំពុងរស់នៅ ។ ជំងឺនេះអាចវិវឌ្ឍន៍ទៅដល់ការចុះខ្សោយសមត្ថភាពផ្នែកបញ្ញា និងអាចឈានទៅដល់ការបាត់បង់ការចងចាំថែមទៀត ។ លោកសាស្ត្រាចារ្យ ខាំប៊ែល បានផ្តល់អនុសាសន៍ឲ្យមានការកែប្រែរបបថ្នាំរបស់ជនជាប់ចោទ និងស្នើឲ្យមានការតែងតាំងអ្នកជំនាញផ្នែកវិកលវិជ្ជា ដើម្បីធ្វើការវាយតម្លៃបន្ថែមទៅលើស្ថានភាពសតិបញ្ញារបស់ជនជាប់ចោទរូបនេះ ។ ការសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ ខាំប៊ែល ទាក់ទងទៅនឹងស្ថានភាពបញ្ញាស្មារតីរបស់ជន ជាប់ចោទ អៀង ធីរិទ្ធ បាននាំឲ្យមានការព្រួយបារម្ភពីមជ្ឈដ្ឋានសាធារណជនទាក់ទងទៅនឹងការធ្វើពុតរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីរួចផុតពីការកាត់ទោសរបស់តុលាការ ។ ដោយសារនៅក្នុងច្បាប់ជាតិក្តី និងច្បាប់អន្តរជាតិក្តីមិនអនុញ្ញាតឲ្យមានការជំនុំជម្រះទោសទៅលើជនដែលមិនមានបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការតតាំងនៅក្នុងសវនាការឡើយ ។ លោក ខាំប៊ែល បានអះអាងថា លោកក៏មានការព្រួយបារម្ភពីបញ្ហានេះ ដោយលោកបានធ្វើការសង្កេតយ៉ាងជិតដល់ ប៉ុន្តែមិនមានសញ្ញាណាមួយដែលបញ្ជាក់ថាជនជាប់ចោទ អៀង ធីរិទ្ធ ព្យាយាមធ្វើការបញ្ឆោត ឬធ្វើពុតជាមួយនឹងលោកឡើយ ។

## ៣) ការសួរដេញដោលពីវិធីសាស្ត្រក្នុងការវាយតម្លៃរបស់អ្នកជំនាញ

សវនាការរយៈពេលបីថ្ងៃ ដែលអង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរៀបចំឡើង គឺមានគោលបំណងបើកឲ្យមានការដេញដោលទៅលើអ្នកជំនាញ គឺលោក ចន ខាំប៊ែល ទាក់ទងទៅនឹងវិធីសាស្ត្រក្នុងការវាយតម្លៃទៅលើបញ្ហាកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា ដែលលោកសាស្ត្រាចារ្យ ខាំប៊ែល បានសន្និដ្ឋាននៅក្នុងរបាយការណ៍របស់ខ្លួន ។ ការសួរដេញដោលនេះ គឺចាប់ផ្តើមដំបូងដោយលោកស្រីចៅក្រម ស៊ីលវៀ ខាតប្រ៊ាយត៍ ដោយផ្តើមសួរពីប្រវត្តិការងារ និងវិធីសាស្ត្រក្នុងការពិនិត្យ និងវាយតម្លៃទៅលើស្ថានភាពសុខភាពរបស់ជនជាប់ចោទរបស់លោកសាស្ត្រាចារ្យ ចន ខាំប៊ែល ។

បន្ទាប់ពីការសួរសំណួររបស់ចៅក្រម ភាគីទាំងអស់ត្រូវបានអនុញ្ញាតឲ្យសួរសំណួរទៅកាន់លោកសាស្ត្រាចារ្យ ខាំប៊ែល ដោយចាប់ផ្តើមដោយភាគីសហមេធាវីការពារក្តីឲ្យជនជាប់ចោទ រួចបន្តមកភាគីសហព្រះរាជអាជ្ញា និងចុងក្រោយគឺភាគីមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ភាគីទាំងអស់ត្រូវបានកម្រិតដោយអង្គជំនុំជម្រះឲ្យសួរត្រឹមតែសំណួរណាដែលមានលក្ខណៈទូទៅប៉ុណ្ណោះ ដោយជៀសវាងរាល់សំណួរទាំងឡាយដែលអាចឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានចំពោះបញ្ហាកាយសម្បទារបស់ជនជាប់ចោទ ។

### ក) ការសួរដេញដោលទៅលើអ្នកជំនាញទាក់ទងនឹងជនជាប់ចោទ អៀង ធីរិទ្ធ

នៅក្នុងពេលសួរដេញដោលនៅក្នុងសវនាការ សាស្ត្រាចារ្យ ខាំប៊ែល បានធ្វើការកត់សម្គាល់ថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺចុះខ្សោយផ្នែកបញ្ញា ដែលអាចបណ្តាលឲ្យមានការបាត់ការចងចាំ ឬមានការ ចុះខ្សោយផ្នែកស្មារតី ។

ក្រោយពីការបញ្ចប់ការសួរដេញដោលរបស់ចៅក្រមទៅលើលោកសាស្ត្រាចារ្យ ខាំប៊ែល លោកស្រីមេធាវី ដាយអាណា អេលីស មេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ បានធ្វើការសួរដេញដោលសាស្ត្រាចារ្យ ខាំប៊ែល ដោយផ្តោតទៅលើជំងឺវង្វេងវង្វាន់ស្មារតី ជំងឺរួមតូចនៃខួរក្បាលផ្នែកខាងមុខ និងសមត្ថភាពចូលរួមសវនាការរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ឆ្លើយតបទៅនឹងសំណួររបស់មេធាវី អៀង ធីរិទ្ធ លោកសាស្ត្រាចារ្យ ខាំប៊ែល បានលើកឡើងថា ជនជាប់ចោទ អៀង ធីរិទ្ធ អាចកើតមានជំងឺវង្វេងវង្វាន់ ដែលជំងឺនេះអាចបណ្តាលឲ្យ អៀង ធីរិទ្ធ បាត់ការចងចាំមិនស្គាល់នូវវត្ថុផ្សេងៗ ហើយមិនអាចធ្វើការផ្ចង់អារម្មណ៍បាន និងអាចធ្វើឲ្យប៉ះពាល់ដល់ស្មារតី និងទំនាក់ទំនងរវាងរាងកាយនិងខួរក្បាល ហើយជំងឺនេះក៏នឹងអាចប៉ះពាល់ទៅដល់ប្រព័ន្ធសរសៃប្រសាទរបស់ជនជាប់ចោទដែរ ។ ចំពោះបញ្ហាខួរក្បាលរបស់ជនជាប់ចោទ អៀង ធីរិទ្ធ លោកសាស្ត្រាចារ្យ ខាំប៊ែល បានលើកឡើងថា ខួរក្បាលផ្នែកខាងមុខរបស់ជនជាប់ចោទមានសភាពរួមតូចជាងមុន ហើយភាពរួមតូចនេះវានឹងធ្វើឲ្យប៉ះពាល់ដល់ការគិតពិចារណា ផ្តល់យោបល់ និងការរៀបចំគំរោងផ្សេងៗ ។



មេធាវីអន្តរជាតិ ដាយអាណា អេលីស

ឆ្លើយតបទៅនឹងសំណួររបស់លោកស្រីមេធាវី ដាយអាណា អេលីស មេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ពាក់ព័ន្ធទៅនឹងសមត្ថភាពចូលរួមការពារខ្លួនប្រកបដោយប្រសិទ្ធិភាពចំពោះមុខតុលាការរបស់ជនជាប់ចោទ អៀង ធីរិទ្ធ លោកសាស្ត្រាចារ្យ ខាំប៊ែល បានលើកឡើងថា អៀង ធីរិទ្ធ មិនអាចយល់ពីភស្តុតាងសាក្សី ដែលប្រឆាំងនឹងខ្លួនឡើយ ។ ជនជាប់ចោទ អៀង ធីរិទ្ធ ក៏មានការលំបាកក្នុងការតតាំងជាមួយភាគីផ្សេងៗ នៅក្នុងសវនាការ ពិបាកយល់ដឹងនីតិវិធី និងលទ្ធផលនៃនីតិវិធីណាស់ និងមានការលំបាកក្នុងការណែនាំមេធាវីរបស់ខ្លួន ហើយមិនអាចចូលរួមសវនាការឲ្យបានពេញលេញនោះទេ ។

លោកសាស្ត្រាចារ្យ ខាំប៊ែល បានបញ្ជាក់យ៉ាងច្បាស់ថា ប៉ុន្តែប្រវត្តិក្រុមគ្រួសាររបស់ជនជាប់ចោទ អៀង ធីរិទ្ធ ធ្លាប់មានម្តាយ និងបងស្រីឈ្មោះ ខៀវ ប៉ុណ្ណារី ដែលសាធារណជនទូទៅស្គាល់ថាជាភរិយារបស់ ប៉ុល ពត កើតមានជំងឺបាត់បង់ផ្នែកបញ្ញាស្មារតីដូចជនជាប់ចោទរូបនេះក៏ដោយ ក៏ជំងឺនេះមិនមែនជាជំងឺតំណពូជឡើយ ។ ជំងឺបាត់បង់ផ្នែកបញ្ញាស្មារតីនេះ វាកើតឡើងតែចំពោះមនុស្សដែលចាប់ផ្តើមឈានចូលដល់វ័យចំណាស់ ហើយ

ចំនួន២០ភាគរយនៃមនុស្សចាស់ដែលមានអាយុលើសពី៨០ឆ្នាំ បានកើតជំងឺនេះ ។ ជំងឺបាត់បង់ផ្នែកបញ្ញាស្មារតីនេះ គឺបណ្តាលមកពីការស្លាប់បាត់បង់នៃកោសិកាខួរក្បាល ដែលបណ្តាលឲ្យអ្នកជំងឺចាប់ផ្តើមមានការចុះខ្សោយផ្នែកការចងចាំវង្វេងវង្វាន់ស្មារតី និងអាចឈានទៅដល់ការបាត់បង់ការចងចាំតែម្តងនាពេលអនាគត ។ លោកសាស្ត្រាចារ្យ ខាំប៊ែល ក៏បានបញ្ជាក់ដែរថា ជនជាប់ចោទ អៀង ធីរិទ្ធ អាចនឹងចូលរួមដំណើរការនីតិវិធីតាមរយៈមធ្យោបាយសោតទស្សន៍បាននៅពេលណាដែលសុខភាពរបស់ជនជាប់ចោទរូបនេះមានលក្ខណៈល្អប្រសើរឡើងវិញ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល ផ្តល់អនុសាសន៍ឲ្យធ្វើការចាត់តាំងអ្នកជំនាញបន្ថែមដើម្បីវាយបន្ថែមលើសមត្ថភាពស្មារតីរបស់អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ។

ក្រោយពីការសួរដេញដោលរបស់លោកស្រី ដាយអាណា អេលីស មេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ទៅលើលោកសាស្ត្រាចារ្យ ខាំប៊ែល រួចមក ភាគីសហព្រះរាជអាជ្ញានិងភាគីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ឱកាសឲ្យធ្វើការសួរសំណួរទៅលើលោកសាស្ត្រាចារ្យ ខាំប៊ែល ទាក់ទងទៅនឹងបញ្ហាកាយសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ទាំងភាគីសហព្រះរាជអាជ្ញា និងភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហាក់បីដូចជាមានការយល់ស្របទៅនឹងការសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ ខាំប៊ែល ទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ភាគីទាំងពីរនេះមិនបានសួរសំណួរដែលមានលក្ខណៈយល់ស្របទាំងស្រុងចំពោះការសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យឡើយ សហព្រះរាជអាជ្ញានិងមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសួរនូវសំណួរតាមរបៀបជាការស្នើសុំទៅលោកសាស្ត្រាចារ្យ ខាំប៊ែល ឲ្យធ្វើការបញ្ជាក់ឲ្យបានច្បាស់ពីវិធីសាស្ត្រទាំងឡាយដែលលោកសាស្ត្រាចារ្យបានប្រើប្រាស់ក្នុងការវាយតម្លៃទៅលើកាយសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ដើម្បីធ្វើឲ្យភាគីទាំងពីរជឿជាក់ថា ការសន្និដ្ឋាននេះធ្វើឡើងដោយមានភាពត្រឹមត្រូវ និងអាចបញ្ជាក់ថាជនជាប់ចោទ អៀង ធីរិទ្ធ ពិតជាមិនមានសមត្ថភាពបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងសវនាការ ។ ភាគីសហព្រះរាជអាជ្ញា ក៏បានសួរទៅលោកសាស្ត្រាចារ្យ ខាំប៊ែល ពីបទដ្ឋានដែលប្រើប្រាស់ធ្វើជាមូលដ្ឋានក្នុងការវាយតម្លៃថាតើលោកសាស្ត្រាចារ្យបានយោងទៅលើបទដ្ឋានណាមួយ ។ ឆ្លើយតបទៅនឹងសំណួរនេះ សាស្ត្រាចារ្យ ខាំប៊ែល បានបញ្ជាក់ថា បទដ្ឋានដែលប្រើប្រាស់ក្នុងការវាយតម្លៃគឺជាបទដ្ឋានដែលតម្រូវដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីធ្វើការវាយតម្លៃដោយផ្អែកទៅលើសមត្ថភាពយល់ដឹងពីនីតិវិធីរបស់តុលាការ សមត្ថភាពយល់ដឹងពីបទចោទប្រកាន់ សមត្ថភាពណែនាំមេធាវីរបស់ខ្លួន មានសមត្ថភាពអាចឆ្លើយតបការចោទប្រកាន់មកលើខ្លួន និងជនជាប់ចោទត្រូវមានសមត្ថភាពគ្រប់គ្រាន់ផ្នែកសតិបញ្ញា ។

### ១) ការសួរដេញដោលទៅលើអ្នកជំនាញទាក់ទងនឹងជនជាប់ចោទ នួន ជា

ទាក់ទៅនឹងកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា លោកសាស្ត្រាចារ្យ ចន ខាំប៊ែល ធ្វើសេចក្តីសន្និដ្ឋានថា នួន ជា មានសមត្ថភាពគ្រប់គ្រាន់អាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបាន ដោយសារជនជាប់ចោទ នួន ជា មានសមត្ថភាពចងចាំបានច្រើន ហើយអាចយល់ពីនីតិវិធី អាចធ្វើការណែនាំមេធាវីរបស់ខ្លួនបាន និងមានការរៀបចំកម្រិតលំដាប់លំដោយនៃព័ត៌មានរបស់ខ្លួនបានយ៉ាងល្អ ។

ឆ្លើយតបទៅនឹងសំណួររបស់លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ លោកសាស្ត្រាចារ្យ ខាំប៊ែល បានលើកឡើងថា ជនជាប់ចោទ នួន ជា មិនមានបញ្ហាសម្បទាក្នុងការចូលរួមសវនាការនោះទេ ហើយចំពោះបញ្ហាសរសៃប្រសាទវិញ មិនមានអ្វីគួរឲ្យព្រួយបារម្ភនោះទេ រីឯជំងឺដាច់សរសៃឈាមខួរក្បាលដែលកើតមានក្នុងឆ្នាំ១៩៨៥ ក៏មិនពាក់ព័ន្ធទៅនឹងការចុះខ្សោយសមត្ថភាពខួរក្បាលនោះដែរ ។ ម្យ៉ាងវិញទៀត នួន ជា អាចមានសមត្ថភាពអង្គុយបានពីពីរទៅបីម៉ោង ហេតុនេះត្រឹមតែបន្ទប់រង់ចាំដែលរៀបចំឡើងសម្រាប់ជនជាប់ចោទដែលមានបញ្ហាសុខភាព មិនអាចចូលរួមដោយផ្ទាល់នៅក្នុងសាលសវនាការ គឺមានលក្ខណៈគ្រប់គ្រាន់ ហើយសម្រាប់រូបជនជាប់ចោទ នួន ជា ក្នុងការចូលរួមនីតិវិធីសវនាការ និងអាចទទួលបានការព្យាបាលពីសំណាក់ក្រុមគ្រូពេទ្យនៅក្នុងករណីចាំបាច់ ។

ឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវី ចាស្តើ ប៉ោវ មេធាវីការពារក្តីរបស់ នួន ជា លោកសាស្ត្រាចារ្យ ឌាំប៊ែល បានលើកឡើងថា ជនជាប់ចោទ នួន ជា បច្ចុប្បន្ននេះមិនមានបញ្ហាជំងឺបេះដូង និងសរសៃឈាមខួរក្បាលទៀតឡើយ ។ ចំណែកឯជំងឺដាច់សរសៃឈាមខួរក្បាលដែលកើតមានពីមុន ក៏មិនមានការប៉ះពាល់ដល់ការចងចាំនិងការផ្តល់អារម្មណ៍របស់ជនជាប់ចោទរូបនេះដែរ ។ ម្យ៉ាងវិញទៀតបញ្ហាស្មារតី និងការផ្តល់អារម្មណ៍របស់ នួន ជា គឺមានលក្ខណៈធម្មតា ។ ដូចនេះជនជាប់ចោទ នួន ជា អាចមានសម្បទាគ្រប់គ្រាន់ក្នុង ការចូលរួមសវនាការ ។

ការសួរដេញដោលរបស់សហមេធាវីការពារឲ្យជនជាប់ចោទ នួន ជា ហាក់បីដូចជាព្យាយាមលើកឡើងពីការខ្វះចន្លោះក្នុងការពិនិត្យ និងវាយតម្លៃទៅលើបញ្ហាកាយសម្បទា និងបញ្ញាស្មារតីទៅលើកូនក្តីរបស់ខ្លួនពីសំណាក់លោកសាស្ត្រាចារ្យ ឌាំប៊ែល ដោយបានសង្កត់ធ្ងន់ថា លោកសាស្ត្រាចារ្យមិនបានធ្វើការពិចារណាទៅលើបញ្ហាសម្ពាធឈាមរបស់ជនជាប់ចោទ នួន ជា ទេ ដែលបញ្ហាសម្ពាធឈាមនេះហើយដែលធ្វើឲ្យ នួន ជា មិនអាចចូលរួមសវនាការបានពេញលេញ ដោយសារមានការលំបាកក្នុងការផ្តល់អារម្មណ៍ ។

នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនលោក ម៉ៃឃើល ដេស្តមេន សហមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា បានលើកឡើងថា ជនជាប់ចោទ នួន ជា មិនទទួលស្គាល់លើរបាយការណ៍ទាំងពីរដែលធ្វើឡើងដោយសាស្ត្រាចារ្យ ឌាំប៊ែល ឡើយ ។ ដោយសារតែលោកសាស្ត្រាចារ្យ ឌាំប៊ែល មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការវាយតម្លៃទៅលើកាយសម្បទារបស់ នួន ជា នោះទេ ពីព្រោះលោកមិនមានជំនាញក្នុងការវាយតម្លៃផ្នែកបញ្ញាស្មារតីក្នុងការចូលរួមសវនាការក្នុងរឿងក្តីព្រហ្មទណ្ឌដូចជាករណីនៅក្នុងសវនាការនាពេលនេះ និងបានស្នើសុំឲ្យមានការតែងតាំងអ្នកជំនាញបន្ថែមទៀតដើម្បីធ្វើការពិនិត្យនិងវាយតម្លៃដោយផ្តោតលើការផ្តល់អារម្មណ៍របស់ជនជាប់ចោទ នួន ជា ។

នៅក្នុងការសួរដេញដោលរបស់ខ្លួនចំពោះលោកសាស្ត្រាចារ្យ ឌាំប៊ែល លោកសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុល បានព្យាយាមធ្វើការចោទសួរពីសំណួរដែលមានលក្ខណៈទូទៅនិងអនុញ្ញាតឲ្យលោកសាស្ត្រាចារ្យ ឌាំប៊ែល ធ្វើការបញ្ជាក់ដោយសង្ខេបពីហេតុផលដែលធ្វើឲ្យលោកសាស្ត្រាចារ្យជឿថា នួន ជា ពិតជាមានកាយសម្បទា និងបញ្ញាស្មារតីគ្រប់គ្រាប់ក្នុងការចូលរួមនៅក្នុងសវនាការ ហើយមិនចាំបាច់តម្រូវឲ្យមានការវាយតម្លៃបន្ថែមទៅលើរូបជនជាប់ចោទ នួន ជា ។

ឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីកសារពារក្តីរបស់ជនជាប់ចោទ នួន ជា សហព្រះរាជអាជ្ញា បានស្នើសុំឲ្យអង្គជំនុំជម្រះច្រានចោលសំណើរសុំចាត់តាំងអ្នកជំនាញបន្ថែមសម្រាប់ នួន ជា ដោយសហព្រះរាជអាជ្ញាបានលើកឡើងថា លោកសាស្ត្រាចារ្យ ឌាំប៊ែល ត្រូវបានតុលាការធ្វើការណែនាំឲ្យអនុវត្តពីរបៀបវាយតម្លៃទៅលើសមត្ថភាពកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទបានយ៉ាងត្រឹមត្រូវ ។ ម្យ៉ាងវិញទៀត នួន ជា មិនបានធ្វើការសហការណ៍ជាមួយអ្នកជំនាញចិត្តសាស្ត្រ នេះបញ្ជាក់ឲ្យឃើញថា នួន ជា មិនមានបញ្ហាផ្នែកស្មារតីនោះទេ ។ កន្លង



សហព្រះរាជអាជ្ញារងអន្តរជាតិ ថារីក អាប់ឌុល នៅក្នុងសាលសវនាការ

មកមេធាវី នួន ជា បានធ្វើសកម្មភាពជាច្រើនដើម្បីការពារជនជាប់ចោទ នួន ជា នេះបានបង្ហាញឲ្យឃើញថា មេធាវីការពារក្ដីរបស់ជនជាប់ចោទ នួន ជា ពិតជាបានទទួលការណែនាំជាច្រើនពីសំណាក់កូនក្ដីរបស់ខ្លួន ។

ចំណែកឯខាងភាគីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោក ពេជ អង្គ បានបញ្ជាក់ថា ខ្លួនមិនមានសំណួរអ្វីត្រូវសួរទៅលោកសាស្ត្រាចារ្យ ខាំប៊ែល ទៀតឡើយ ដោយសារតែនៅក្នុងដំណើរការនីតិវិធី លោកសាស្ត្រាចារ្យបានបញ្ជាក់យ៉ាងច្បាស់លាស់ថា ជនជាប់ចោទ នួន ជា ពិតជាមានកាយសម្បទានិងបញ្ញាស្មារតីសមស្របក្នុងការចូលរួមនៅក្នុងសវនាការ ។ ក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការឆ្លើយតបទៅខាងសហមេធាវីការពារក្ដីរបស់ជនជាប់ចោទ នួន ជា ថា តាមរយៈសវនាការប៉ុន្មានថ្ងៃនេះ ឃើញថាជនជាប់ចោទ នួន ជា ដែលមានអាយុ៨៥ឆ្នាំរូបនេះ មើលទៅពិតជាមិនមានអ្វីដែលគួរឲ្យបារម្ភថាមិនអាចចូលរួមក្នុងសវនាការបានឡើយ ។

## ៤) វត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការ

នៅក្នុងសវនាការរយៈពេលទាំងបីថ្ងៃ វត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការគឺជារឿងដែលគួរឲ្យចាប់អារម្មណ៍បំផុត ដោយសារតែសវនាការដែលប្រព្រឹត្តធ្វើឡើងស្ទើរតែគ្មានវត្តមាននៃជនជាប់ចោទនៅក្នុងបន្ទប់សវនាការឡើយ ។ ការស្នើសុំចាកចេញពីបន្ទប់សវនាការជាបន្តបន្ទាប់ពីសំណាក់ជនជាប់ចោទដើម្បីត្រឡប់ទៅបន្ទប់ឃុំឃាំង ឬបន្ទប់រង់ចាំ ត្រូវបានអះអាងដោយមេធាវីការពារក្ដីរបស់ជនជាប់ចោទថា បណ្ដាលមកពីបញ្ហាសុខភាពរបស់កូនក្ដីរបស់ខ្លួនដែលមិនអាចអង្គុយ នៅក្នុងបន្ទប់សវនាការបាន ។

បញ្ហាវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការបានធ្វើឲ្យមានការលើកឡើងជាច្រើនពីសំណាក់គ្រប់ភាគីនៅក្នុងសវនាការរហូតទៅដល់ធ្វើឲ្យចៅក្រមសម្រេចចេញសេចក្ដីសម្រេចតម្រូវឲ្យមានការបញ្ជាក់ពីក្រុមគ្រូពេទ្យមុននឹងអនុញ្ញាតឲ្យជនជាប់ចោទអាចចាកចេញពីបន្ទប់សវនាការដោយសារមានបញ្ហាសុខភាព ។

ទោះបីជាសវនាការដែលរៀបចំឡើងគឺដើម្បីបើកឲ្យមានការសួរដេញដោលទៅលើអ្នកជំនាញទាក់ទងនឹងស្ថានភាពកាយសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា ក៏ដោយ ក៏នៅក្នុងពេលសវនាការ សាធារណជនបានសង្កេតឃើញមានវត្តមានរបស់ជនជាប់ចោទ អៀង សារី នៅក្នុងបន្ទប់សវនាការជាមួយនិងជនជាប់ចោទផ្សេងទៀត ។ វត្តមាននេះ គឺដោយសារតែជនជាប់ចោទ អៀង សារី ចូលសវនាការក្នុងឋានៈជាអ្នកសង្កេតការណ៍តែប៉ុណ្ណោះ ដូច្នេះមិនមានរបៀបវារៈណាមួយដែលនឹងត្រូវលើកឡើងទាក់ទងនឹងជនជាប់ចោទ អៀង សារី នោះទេ ។

### ក) វត្តមានរបស់ជនជាប់ចោទ នួន ជា

នៅក្នុងដំណើរការនីតិវិធីនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ជាថ្ងៃទីមួយនៃសវនាការ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចអនុញ្ញាតតាមការស្នើសុំចំនួនពីររបស់សហមេធាវីការពារក្ដីឲ្យជនជាប់ចោទ នួន ជា គឺសុំឲ្យកូនក្ដីរបស់ខ្លួនទៅបន្ទប់ឃុំឃាំងវិញដោយសារមូលហេតុសុខភាព និងស្នើសុំឲ្យជនជាប់ចោទ នួន ជា អាចឡើងថ្លែងពីមតិយោបល់យល់ឃើញរបស់ខ្លួន ។ នៅក្នុងសេចក្ដីថ្លែងការណ៍របស់ខ្លួន ជនជាប់ចោទ នួន ជា បានលើកឡើងថាៈ

១) ខ្លួនចង់មានវត្តមានក្នុងសវនាការដើម្បីភាពយុត្តិធម៌ ។

២) ក្នុងករណីដែលសុខភាពអំណោយផល ខ្លួននឹងចូលរួមក្នុងដំណើរការនីតិវិធីដើម្បីស្វែងរកការពិត មានប្រយោជន៍តាមសំណូមពររបស់ប្រជាជនកម្ពុជា ។

៣) សុខភាពរបស់ខ្លួនមានសភាពទ្រុឌទ្រោមយ៉ាងខ្លាំងពិសេសបញ្ហាផ្ចង់អារម្មណ៍ដែលមិនអាចអង្គុយស្ដាប់បានយូរឡើយ ហើយអានបានត្រឹមតែក្នុងរយៈពេលមួយម៉ោងទៅមួយម៉ោងកន្លះប៉ុណ្ណោះ ក្រោយមកមិនអាចយល់ពីដំណើរការតុលាការបានទៀតឡើយ ទោះបង្ខំខ្លួនឯងឲ្យដេកមើលឬស្ដាប់ទៀតក៏មិនអាចយល់បានដែរ ។

៤) ខ្លួនយល់ឃើញថាបន្ទប់រង់ចាំដែលតុលាការរៀបចំឡើងសម្រាប់ជនជាប់ចោទចូលរួមសវនាការ តាមរយៈមធ្យោបាយសោតទស្សន៍ គឺគ្មានប្រយោជន៍សម្រាប់ខ្លួនទេ ព្រោះបន្ទាប់ពីរយៈពេលខាងលើនេះ ខ្លួនមិនអាចផ្ចង់អារម្មណ៍បានទៀតឡើយ ។

៥) ជនជាប់ចោទ នួន ជា យល់ថា លោកសាស្ត្រាចារ្យ ខាំប៊ែល មិនបានពិនិត្យចំពោះបញ្ហាផ្ចង់អារម្មណ៍របស់ខ្លួននោះទេ ។

៦) ខ្លួននឹងស្នើទៅអង្គជំនុំជម្រះឲ្យបន្ថែមអ្នកជំនាញម្នាក់ទៀតដើម្បីពិនិត្យពីបញ្ហាផ្លូវអារម្មណ៍ ។

ជនជាប់ចោទ នួន ជា នៅតែបន្តស្នើសុំទៅអង្គជំនុំជម្រះដើម្បីចាកចេញពីបន្ទប់សវនាការ ទៅបន្ទប់ឃុំឃាំងសាជាថ្មីនៅក្នុងដំណើរការសវនាការថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ជាសវនាការថ្ងៃទីពីរ ដោយខ្លួនលើកឡើងពីបញ្ហាឈឺក្បាល ដែលមិនអាចឲ្យខ្លួនអង្គុយយូរក្នុងសវនាការបាន ។ ដោយសារនៅក្នុងដំណើរការសវនាការថ្ងៃទីពីរ មិនមានរបៀបវារៈទាក់ទងនឹងបញ្ហារបស់ជនជាប់ចោទ នួន ជា តុលាការបានសម្រេចអនុញ្ញាតឲ្យ នួន ជា អាចចាកចេញទៅសម្រាកតាមដានសកម្មភាពនៅក្នុងសវនាការពីបន្ទប់រង់ចាំដែលបានរៀបចំទុកដោយមន្ត្រីតុលាការ និងបានបង្គាប់ឲ្យ នួន ជា ត្រូវត្រឡប់មកបង្ហាញមុខនៅក្នុងបន្ទប់សវនាការនៅក្នុងពេលរសៀល ។ បន្ទាប់ពីការចាប់ផ្តើមដំណើរការកិច្ចនីតិវិធីសវនាការនាពេលរសៀលបានមួយរយៈខ្លី ជនជាប់ចោទ នួន ជា បានស្នើសុំអង្គជំនុំជម្រះឡើងបញ្ចេញមតិយោបល់ជាលើកទីពីរ ។ ក្រោយពេលទទួលបានការអនុញ្ញាតពីអង្គជំនុំជម្រះ ជនជាប់ចោទ នួន ជា បានធ្វើសេចក្តីថ្លែងទៅអង្គសវនាការថា៖ «សុខភាពរបស់ខ្លួនសព្វថ្ងៃមិនដូចកាលពីមុនទេ ដោយសារតែភាពជរាធ្វើឲ្យខ្លួនកាន់តែខ្សោយទៅៗ ហើយមិនមែនខ្លួនមិនជឿទៅលើថ្នាំពេទ្យ ឬគ្រូពេទ្យនោះទេប៉ុន្តែ នួន ជា ជឿថាមានតែខ្លួនទេដែលដឹងពីសុខភាពខ្លួនឯងច្បាស់» ។

នៅក្នុងដំណើរការសវនាការថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ ជាសវនាការថ្ងៃទីបី ជនជាប់ចោទ នួន ជា នៅតែបន្តស្នើសុំទៅអង្គជំនុំជម្រះចាកចេញទៅសម្រាកនៅបន្ទប់ឃុំឃាំងសាជាថ្មីម្តងទៀតតាមរយៈមេធាវីរបស់ខ្លួន ដោយសំអាងទៅលើហេតុផលសុខភាពដូចគ្នានឹងកាលពីពីរថ្ងៃមុន ហើយជនជាប់ចោទ នួន ជា បដិសេធមិនព្រមចូលរួមសវនាការនៅពីបន្ទប់រង់ចាំឡើយ ដោយលើកឡើងថាការចូលរួមសវនាការតាមរយៈបន្ទប់រង់ចាំនោះមិនមានប្រយោជន៍អ្វីដល់កូនក្តីរបស់ខ្លួនឡើយ ។ ការលើកឡើងដូច្នេះ ត្រូវបានលោកស្រីចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ ធ្វើការពន្យល់ទៅមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា វិញថា ការរៀបចំបន្ទប់រង់ចាំនេះឡើងគឺដើម្បីសម្រួលដល់ការចូលរួមរបស់ជនជាប់ចោទ នៅពេលណា


នួន ជា និងសហមេធាវីការពារក្តីនៅក្នុងសាលសវនាការ ឆ្នាំ២០១១

រូបថត : អ.វ.ត.ក

ដែលជនជាប់ចោទមានបញ្ហាសុខភាពមិនអាចចូលរួមដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការបាន ។ ដូច្នេះការស្នើសុំរបស់មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា មិនមានហេតុផលសមរម្យដែលអាចឲ្យអង្គជំនុំជម្រះសម្រេចអនុញ្ញាតបានឡើយ ។ អង្គជំនុំជម្រះបានសម្រេចថា ជនជាប់ចោទ នួន ជា ត្រូវនៅចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈមធ្យោបាយសោតទស្សន៍ ដោយមិនអនុញ្ញាតឲ្យទៅបន្ទប់ឃុំឃាំងវិញឡើយ ។ ជាងនេះទៅទៀត អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមួយតម្រូវឲ្យជនជាប់ចោទត្រូវមានរបាយការណ៍សុខភាពពីមន្ត្រីពេទ្យរបស់អង្គជំនុំជម្រះជាមុន មុននឹងធ្វើការស្នើសុំចាកចេញពីបន្ទប់សវនាការ ។

### ៤) វត្តមានរបស់ជនជាប់ចោទ អៀង ធីរិទ្ធ

មិនខុសគ្នានឹងជនជាប់ចោទ នួន ជា ឡើយ នៅក្នុងពេលសវនាការ ជនជាប់ចោទ អៀង ធីរិទ្ធ បានស្នើសុំអង្គជំនុំជម្រះដើម្បីចាកចេញទៅសម្រាកនៅបន្ទប់ឃុំឃាំងតាមរយៈមេធាវីរបស់ខ្លួន ដោយអះអាងពីបញ្ហាសុខភាពមិនអំណោយផល ដែលមិនអាចអោយខ្លួនអាចចូលរួមនៅក្នុងសវនាការបន្តទៀតបាន ។

នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ជាថ្ងៃទីមួយនៃសវនាការ មេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ បានស្នើសុំទៅអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនទៅបន្ទប់ឃុំឃាំងវិញ ដោយសារថាកូនក្តីរបស់ខ្លួនឈឺជង្គង់ ។ ប៉ុន្តែការស្នើសុំទៅបន្ទប់ឃុំឃាំងរបស់ជនជាប់ចោទនេះ ត្រូវបានបដិសេធដោយអង្គជំនុំជម្រះ ដោយសារស្ថានភាពជំងឺរបស់ជនជាប់ចោទមិនមានអ្វីធ្ងន់ធ្ងរ និងអាចចូលរួមសវនាការពីបន្ទប់រង់ចាំ តាមរយៈមធ្យោបាយសោតទស្សន៍បាន ។

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ជាថ្ងៃទីពីរនៃវនាការ ជនជាប់ចោទ អៀង ធីរិទ្ធ បានចូលរួមក្នុងសវនាការសួរដេញដោលទៅលើរបាយការណ៍ស្តីពីសម្បទារបស់ខ្លួនស្ទើរពេញមួយថ្ងៃ ។ ប៉ុន្តែនៅក្រោយពេលដែលអង្គជំនុំជម្រះចាប់ផ្តើមបន្តដំណើរនីតិវិធីសួរចេញដេញដោលពីស្ថានភាពកាយសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បានបន្តិច ស្រាប់តែជនជាប់ចោទ អៀង ធីរិទ្ធ បានងើបឡើង និងដើរចេញពីបន្ទប់សវនាការដោយមិនខ្វល់ពីការហាមឃាត់របស់អនុរក្សនៃមន្ទីរឃុំឃាំងដែលនៅរក្សាសន្តិសុខរបស់ខ្លួននិងដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះ ។

សកម្មភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលបានងើបពីកៅអី ហើយដើរចេញក្រៅបន្ទប់សវនាការ ដោយមិនមានការអនុញ្ញាតពីចៅក្រមនេះ បានបង្ហាញថា ស្ថានភាពសតិបញ្ញាស្មារតីរបស់ជនជាប់ចោទកំពុងតែស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ ។ សាធារណជន ភាគច្រើនដែលអង្គុយតាមដានសកម្មភាពនៅក្នុងសាលសវនាការ ហាក់បីដូចជាគិតថា វាគ្រាន់តែជាការប៉ុនប៉ងរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការធ្វើដូច្នេះ ដើម្បីឲ្យសាធារណជនឃើញថា ស្ថានភាពបញ្ញាស្មារតីរបស់ខ្លួនកំពុងតែធ្លាក់ដុនដាបតែប៉ុណ្ណោះ ពីព្រោះនៅមុនពេលដែល អៀង ធីរិទ្ធ ដើរចេញពីក្នុងបន្ទប់សវនាការ សាធារណជនឃើញជនជាប់ចោទ អៀង ធីរិទ្ធ បានអង្គុយនិយាយលេងសើចទៅកាន់សហមេធាវីការពារក្តីរបស់ខ្លួន ហាក់បីដូចជាមិនមានអ្វីខុសប្លែកពីធម្មតាឡើយ ។

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ ជាថ្ងៃទីបីនៃសវនាការ បានប្រព្រឹត្តទៅដោយគ្មានវត្តមានរបស់ ជនជាប់ចោទ អៀង ធីរិទ្ធ ឡើយ ដោយសារអង្គជំនុំជម្រះលើកឡើងថា នៅក្នុងសវនាការថ្ងៃទីបី ជនជាប់ចោទ អៀង ធីរិទ្ធ អាចស្នើសុំមិនចូលរួមនៅក្នុងនីតិវិធីសវនាការបាន ព្រោះវាជាសវនាការដោយឡែកដែលផ្តោតទៅលើការសួរដេញដោលទាក់ទងនឹងបញ្ហាកាយសម្បទារបស់ជនជាប់ចោទ នួន ជា ។

### ៥) បញ្ហាផ្សេងៗ

នៅក្នុងដំណើរការសវនាការស្តីពីសម្បទារបស់ជនជាប់ចោទ នួន ជា និង អៀង ធីរិទ្ធ គឺត្រូវបានធ្វើជាសាធារណៈក្នុងរយៈពេលបីថ្ងៃ ។ សាធារណជនសង្កេតឃើញមេធាវីរបស់ នួន ជា និង អៀង ធីរិទ្ធ មានជំហរផ្សេងគ្នាពាក់ព័ន្ធទៅនឹងការធ្វើសវនាការជាសាធារណៈនេះ ។ មេធាវីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បានបញ្ជាក់ទៅអង្គជំនុំជម្រះជាសាធារណៈថា ខ្លួនមិនមានបំណងណាមួយឲ្យដំណើរការសវនាការប្រព្រឹត្តទៅជាអសាធារណៈពាក់ព័ន្ធទៅនឹងសម្បទារបស់ អៀង ធីរិទ្ធ ឡើយ ។ ផ្ទុយពីគោលជំហរនេះ មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា បានធ្វើការស្នើសុំទៅអង្គជំនុំជម្រះឲ្យបើកសវនាការប្រព្រឹត្តទៅជាអសាធារណៈសម្រាប់ជនជាប់ចោទ នួន ជា ដោយបានលើកឡើងពីអត្ថប្រយោជន៍នៃការ

រក្សាការណ៍សម្ងាត់របស់ជនជាប់ចោទ ។ សំណើរនេះត្រូវបានអង្គជំនុំជម្រះសម្រេចច្រានចោលដោយអង្គជំនុំជម្រះយល់ឃើញថា សវនាការដែលបានប្រព្រឹត្តទៅអស់រយៈពេលពីរថ្ងៃកន្លងមក ព័ត៌មានដែលទាក់ទងទៅនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទត្រូវបានលាតត្រដាងស្ទើរតែទាំងស្រុងរួចទៅហើយ ។ ប៉ុន្តែអង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីរបស់ នួន ជា ធ្វើការជំទាស់ទៅលើការបង្ហាញឯកសារណាមួយដែលខ្លួនយល់ថាមានការប៉ះពាល់ដល់អត្ថប្រយោជន៍កូនក្តីរបស់ខ្លួន ។ ទោះបីជាសវនាការធ្វើសាធារណៈទាំងស្រុងក៏ដោយ ក៏សាធារណជនសង្កេតឃើញថា "ភាគីទាំងអស់មិនត្រូវបានអនុញ្ញាតឲ្យសួរសំណួរដែលមានលក្ខណៈជាសំណួរបែបសន្និដ្ឋានឡើយ ដោយអង្គជំនុំជម្រះធ្វើការរំឭកដល់ភាគីថា "ភាគីទាំងអស់ត្រូវបានអនុញ្ញាតឲ្យសួរតែទៅលើសំណួរទូទៅតែប៉ុណ្ណោះ ។ ចំណែកសំណួរជាក់លាក់ គឺមិនត្រូវបានអនុញ្ញាតឲ្យលើកឡើងឡើយ" ។

ចំពោះការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់របស់ភាគីដែលពាក់ព័ន្ធឃើញថា សវនាការដោយឡែកទាក់ទងទៅនឹងសម្បទារបស់ជនជាប់ចោទ នួន ជា ភាគីទាំងអស់មានឱកាសក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដើម្បីបញ្ចប់ការសួរដេញដោល និងបានលើកសំណើរសុំផ្សេងៗដល់អង្គជំនុំជម្រះ ។ ប៉ុន្តែសម្រាប់សវនាការដោយឡែកលើសម្បទារបស់ជនជាប់ អៀង ធីរិទ្ធ ភាគីទាំងអស់មិនបានធ្វើសេចក្តីសន្និដ្ឋាន ឬសំណើរសុំផ្សេងៗរបស់ខ្លួនក្រោយពេលបញ្ចប់ការសួរដេញដោលនៅក្នុងសវនាការឡើយ ។

## ៦) ការយល់ឃើញទូទៅ

***ហេតុអ្វីជនជាប់ចោទ នួន ជា ស្នើសុំឡើងធ្វើសេចក្តីថ្លែងការណ៍?***

នៅខណៈពេលដែលសាធារណជនដឹងជាទូទៅថា សវនាការបឋមស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការគឺជាបញ្ហាប្រឈមមួយដែលអាចនាំឲ្យមានការពន្យា ឬផ្អាកនីតិវិធីកាត់ទោសជនជាប់ចោទជាស្ថាពរ ក្នុងករណីដែលជនជាប់ចោទត្រូវបានតុលាការរកឃើញថា មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ ។ ជនជាប់ចោទ នួន ជា ឆ្លៀតឱកាសធ្វើសេចក្តីថ្លែងការណ៍ជាចំដោយឡែកមួយ ដែលមានប្រាំមួយចំណុចដូចបានរាប់នៅក្នុងចំណុច"ក" វត្តមានរបស់ជនជាប់ចោទ នួន ជា ។

ហេតុអ្វីបានជាជនជាប់ចោទ នួន ជា លើកអំពីបញ្ហាទាំងនេះឡើង?

ទិដ្ឋភាពច្បាប់ពីរបានធ្វើការឆ្លើយតបចំពោះការលើកឡើងនេះគឺ :

ទី១) គោលការណ៍ជំនុំជម្រះក្តីត្រូវមានវត្តមានជនជាប់ចោទនិង

ទី២) គោលការណ៍នៃការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។

### ១) គោលការណ៍ជំនុំជម្រះក្តីត្រូវមានវត្តមានជនជាប់ចោទ :

វិធាន៨១នៃវិធានផ្ទៃក្នុងចែងថា "ការជំនុំជម្រះត្រូវធ្វើឡើងដោយមានវត្តមានជនជាប់ចោទ លើកលែងតែមានបទបញ្ញត្តិចែងផ្សេងពីនេះ ។....នៅពេលដែលមានមូលហេតុសុខភាព ឬមូលហេតុធ្ងន់ធ្ងរដទៃទៀត ជនជាប់ចោទមិនអាចចូលរួមដោយផ្ទាល់ចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែរូបកាយនិងស្មារតីសមស្របអាចចូលរួមក្នុងដំណើរការនីតិវិធីបាន អង្គជំនុំជម្រះអាចបន្តនីតិវិធីដោយមិនមានវត្តមានរបស់ជនជាប់ចោទដោយមានការយល់ព្រមពីជនជាប់ចោទ..." ។

យោងតាមវិធាននេះ កិច្ចដំណើរការនីតិវិធីគឺត្រូវតែមានវត្តមានរបស់ជនជាប់ចោទ ។ ប៉ុន្តែកិច្ចដំណើរការនីតិវិធីអាចប្រព្រឹត្តទៅដោយគ្មានវត្តមានរបស់ជនជាប់ចោទបាន ក្នុងករណីដែលជនជាប់ចោទៈ

ទីមួយ : ជនជាប់ចោទមានមូលហេតុសុខភាព ឬមូលហេតុធ្ងន់ធ្ងរដទៃទៀត ។

ទីពីរ : ត្រូវមានការយល់ព្រមពីជនជាប់ចោទឲ្យដំណើរការនីតិវិធីប្រព្រឹត្តទៅដោយគ្មានវត្តមានរបស់ខ្លួន ។

ជនជាប់ចោទ នួន ជា បានលើកឡើងថា ខ្លួនចង់ចូលរួមសវនាការ ប៉ុន្តែខ្លួនមានបញ្ហាសុខភាពពាក់ព័ន្ធនឹងការផ្ចង់អារម្មណ៍ ។ តាមគោលការណ៍ច្បាប់ កិច្ចដំណើរការនីតិវិធីអាចនឹងត្រូវបានផ្អាកដើម្បីគោរពនូវគោលការណ៍កាត់ទោសដោយមានវត្តមានរបស់ជនជាប់ចោទ ។ ផ្អែកទៅលើលក្ខខណ្ឌច្បាប់ ដើម្បីអាចធ្វើកិច្ចដំណើរការនីតិវិធីដោយគ្មានវត្តមានជនជាប់ចោទដូចបានរៀបរាប់

ខាងលើ និងអ្វីដែលជនជាប់ចោទ នួន ជា បានលើកឡើង សាធារណជនទូទៅអាចនឹងធ្វើការសន្និដ្ឋានថាជនជាប់ចោទ នួន ជា កំពុងតែចង់ប្រើប្រាស់នូវគោលការណ៍ជំនុំជម្រះក្តីត្រូវមានវត្តមានរបស់ជនជាប់ចោទ ដែលជាគោលការណ៍ដ៏មានប្រសិទ្ធិភាពដើម្បីរារាំងកិច្ចដំណើរការនីតិវិធីក្នុងការកាត់ទោសមកលើរូបខ្លួន ។ ប្រសិនបើសាធារណជនធ្វើការសន្និដ្ឋានជាទូទៅដូច្នេះមែន ពិតជារឿងមួយពិបាកចំពោះជនជាប់ចោទ នួន ជា ក្នុងការបង្ហាញភ័ស្តុតាងដើម្បីទៅនឹងការលើកឡើងនេះ គោលការណ៍នៃការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលជាគោលការណ៍សំខាន់ដែលអាចនាំឲ្យតុលាការធ្វើការពន្យា ឬផ្អាកនីតិវិធីកាត់ទោសជនជាប់ចោទជាស្ថាពរ នឹងត្រូវបានគេយកមកអនុវត្ត ក្នុងករណីដែលជនជាប់ចោទមានបញ្ហាដូចបានលើកឡើងខាងលើនេះមែន ។

ប្រហែលជាមិនមែនជាភាពចៃដន្យទេ នៅពេលដែលជនជាប់ចោទ នួន ជា បានធ្វើការលើកឡើងនូវប្រាំមួយចំណុចខ្លីៗពាក់ព័ន្ធ


សាធារណជនកំពុងតម្រង់ជួរចូលក្នុងសាលសវនាការ

ឲ្យសាធារណជនជឿថា ខ្លួនមិនមានសមត្ថភាពយល់ដឹងពីនីតិវិធីរបស់តុលាការ ។

### ២) គោលការណ៍នៃការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌

ជនជាប់ចោទ នួន ជា បានលើកឡើងថា ៖ “ដោយសារខ្លួនមិនអាចធ្វើការផ្តង់អារម្មណ៍បាន ដូចនេះធ្វើឲ្យខ្លួនមិនអាចយល់ដឹងអំពីកិច្ចដំណើរការនីតិវិធីរបស់តុលាការបាន” ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាផ្ទាល់ខ្លួនរបស់ខ្លួន ។ សេចក្តីថ្លែងការណ៍ធ្វើដោយសាមញ្ញ ប៉ុន្តែពោរពេញទៅដោយអត្ថន័យផ្លូវច្បាប់ ធ្វើឲ្យសាធារណជនពិបាកនឹងជឿថាជនជាប់ចោទ នួន ជា ពិតជាមិនយល់ដឹងពីកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។ មានការសន្និដ្ឋានជាផ្លូវការមួយរបស់សាស្ត្រាចារ្យ ខាំប៉ែល ទៅសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា ដោយលោកសាស្ត្រាចារ្យ ខាំប៉ែល បានលើកឡើងថា “ការធ្វើសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា នៅ

ពេលសវនាការ គឺមានការបង្ហាញយ៉ាងច្បាស់ថា នួន ជា មានការយល់ច្បាស់អំពីស្ថានភាពរបស់ខ្លួន យល់ដឹងពីអ្វីដែលអង្គជំនុំជម្រះកំពុងតែធ្វើដំណើរការនីតិវិធី បញ្ហារបស់ខ្លួនដែលកំពុងតែត្រូវបានពិភាក្សានៅក្នុងសវនាការ និងកម្រិតលំដាប់លំដោយនៃព័ត៌មានដែលអាចនឹងចាត់ទុកថាជាអ្នកមានស្មារតីគ្រប់គ្រាន់» ។

ដូចនេះអ្វីដែលសាធារណជននឹងអាចកត់សម្គាល់ឃើញគឺជនជាប់ចោទ នួន ជា កំពុងតែព្យាយាមប្រើប្រាស់នីតិវិធីដែលមានចែងក្នុងវិធានផ្ទៃក្នុងឲ្យអស់ពីលទ្ធភាពក្នុងការការពារខ្លួនឲ្យផុតពីការដាក់ទោស ។

## ការបញ្ចេញកាយវិការរបស់ នួន ជា នៅក្នុងសវនាការជាយុទ្ធសាស្ត្រ?

វត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការ គឺពិតជាមានសារសំខាន់ដើម្បីឲ្យការជំនុំជម្រះប្រព្រឹត្តទៅដោយត្រឹមត្រូវនិងយុត្តិធម៌ ។ នៅក្នុងកំឡុងពេលសវនាការ ការចូលរួមរបស់ជនជាប់ចោទបានធ្វើឲ្យសាធារណជនមានការចាប់អារម្មណ៍យ៉ាងខ្លាំង ។ ជនជាប់ចោទ នួន ជា តែងតែស្នើសុំបោះបង់សិទ្ធិរបស់ខ្លួនក្នុងការចូលរួមក្នុងសវនាការ និងបានស្នើសុំទៅកាន់បន្ទប់ឃុំឃាំង ។ រាល់ការស្នើសុំរបស់ជនជាប់ចោទ គឺមានពាក់ព័ន្ធទៅនឹងសុខភាពរបស់ជនជាប់ចោទជានិច្ច ។ ការចូលរួមរបស់ជនជាប់ចោទ ហាក់បីដូចជាគ្រាន់តែចង់បង្ហាញឲ្យសាធារណជនឃើញថា ខ្លួនមានបំណងចង់ចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការសវនាការ តែដោយសារបញ្ហាសុខភាពទើបធ្វើឲ្យខ្លួនមានការអាក់ខានមិនអាចចូលរួមបាន ។ ជនជាប់ចោទតែងតែលើកឡើងថា ខ្លួនចង់ចូលរួមនៅក្នុងដំណើរការសវនាការ តែជនជាប់ចោទតែងតែស្នើសុំទៅកាន់បន្ទប់ឃុំឃាំងទៅវិញ ។ នៅក្នុងបន្ទប់រង់ចាំ មាន គ្រែ កៅអី ទូរទស្សន៍ មានគ្រូពេទ្យ និងមធ្យោបាយសម្រាប់ទំនាក់ទំនងទៅកាន់មេធាវីរបស់ខ្លួននៅក្នុងសវនាការ ។ បន្ទប់រង់ចាំគឺមិនខុសពីបន្ទប់ឃុំឃាំងនោះទេ ហើយថែមទាំងមានភាពងាយស្រួលជាងមន្ទីរឃុំឃាំងទៅទៀត តែជនជាប់ចោទតែងតែស្នើសុំទៅមន្ទីរឃុំឃាំងជានិច្ច ។ ចំពោះបញ្ហាផ្តង់អារម្មណ៍នៅក្នុងដំណើរការសវនាការនោះ គឺហាក់ដូចជាបង្កើតនូវមន្ទិលសង្ស័យដល់សាធារណជនថា តើ នួន ជា ពិតជាមិនអាចផ្តង់អារម្មណ៍បានមែនឬយ៉ាងណា? នៅក្នុងដំណើរការសវនាការនៅថ្ងៃទី១ និងទី២ នោះ ជនជាប់ចោទបានចូលរួមសវនាការរយៈពេលពីរទៅបីម៉ោង ថែមទាំងបានធ្វើការថ្លែងចំណាប់អារម្មណ៍មួយចំនួនយ៉ាងជាក់លាក់ទៀតផង ។ តាមរយៈរបាយការណ៍របស់ពេទ្យដែលបានពិនិត្យកាលពីម៉ោង១១ និង៤៥នាទី ដែលបានធ្វើឡើងក្រោយពីការស្នើសុំទៅកាន់មន្ទីរឃុំឃាំងដែលជនជាប់ចោទ នួន ជា បានអះអាងថា ខ្លួនមិនអាចយល់ដឹងនីតិវិធីតុលាការ លោកសាស្ត្រាចារ្យ ខាំប៊ែល បានឲ្យដឹងថា ជនជាប់ចោទ នួន ជា មានសម្ពាធឈាមធម្មតា ហើយមិនមានបញ្ហាសសៃឈាមនោះទេ ហើយចំពោះអុកស៊ីសែនមិនមានបញ្ហាដល់បេះដូងឡើយ ។ ដោយពិនិត្យទៅលើរបាយការណ៍ដែលពេទ្យបានពិនិត្យភ្លាមៗ និងតាមរយៈការបកស្រាយរបស់លោកសាស្ត្រាចារ្យ ខាំប៊ែល អង្គជំនុំជម្រះសម្រេចឲ្យជនជាប់ចោទ នួន ជា ចូលរួមនីតិវិធីសវនាការពីបន្ទប់រង់ចាំ ដោយសារអង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទ នួន ជា មិនមានភ័ស្តុតាងណាមួយដែលបញ្ជាក់ថា ខ្លួនមានបញ្ហាសុខភាពដែលមិនអាចចូលរួមសវនាការបាននោះទេ ។

## ៧) សន្និដ្ឋាន

សរុបសេចក្តីមក សវនាការបឋមពីថ្ងៃទី២៩ ដល់ទី៣១ ខែសីហា ឆ្នាំ២០១១ គឺជាសវនាការដែលធ្វើឡើងដើម្បីអនុញ្ញាតឲ្យសហមេធាវីការពារក្តី អៀង ធីរិទ្ធ និង នួន ជា សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចសួរសំណួរទៅលោកសាស្ត្រាចារ្យ ចន ខាំប៊ែល២ និងបង្ហាញនូវអំណះអំណាងផ្សេងៗអំពីការធ្វើសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍របស់លោកសាស្ត្រាចារ្យ ខាំប៊ែល ទាក់ទងនឹងកាយសម្បទានិងបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា និង អៀង ធីរិទ្ធ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅមិនទាន់មានសេចក្តីសម្រេចជាផ្លូវការណាមួយពាក់ព័ន្ធទៅនឹងសម្បទារបស់ជនជាប់ចោទ នួន ជា និង អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការឡើយ ។ ការសម្រេចយ៉ាងណានោះ គឺជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះ ដោយផ្អែកលើរបាយការណ៍របស់អ្នកជំនាញនិងអំណះអំណាងរបស់ភាគីទាំងអស់ដោយអនុលោមតាមបទដ្ឋានដែលអង្គជំនុំជម្រះបានណែនាំអ្នកជំនាញឲ្យយកមកធ្វើជាមូលដ្ឋានក្នុងការពិនិត្យនិងវាយតម្លៃទៅលើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទក្នុងការចូលរួមនៅក្នុងសវនាការ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥
ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨
អ៊ីម៉ែល : *dccam@online.com.kh*
គេហទំព័រ : *www.dccam.org* ឬ *www.cambodiatribunal.org*

គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ
*John D. and Catherine T. MacArthur Foudation* ។



***ឌី សុជាតា***

***សុជាតា*** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេសនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



***គីម ម៉ារីយ៉ាន***

***ម៉ារីយ៉ាន*** បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ម៉ារីយ៉ាន ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



***លឹម ជ័យទត្ត***

***ជ័យទត្ត*** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



***ចាន ប្រាថ្នា***

***ប្រាថ្នា*** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវី នៅកម្ពុជា ។




មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែកញ្ញា ឆ្នាំ២០១១